# ព្រះគ្រីស្ទដ៏មានព្រះជន្មរស់

## ទីបន្ទាល់នៃពួកសាវក

### ព្រះវិហារសាសនាព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

នៅពេលយើងធ្វើបុណ្យរំឭកដល់ថ្ងៃកំណើតនៃព្រះយេស៊ូវគ្រីស្ទ ពីរពាន់ឆ្នាំមកហើយ នោះយើងសូមថ្វាយនូវទីបន្ទាល់របស់យើង អំពីសគុណភាពនៃការបូជាដ៏មហិមារបស់ទ្រង់ ដែលធួននឹងបាប ។ សូម្បីតែមួយក៏គ្មានសោះ ដែលឥទ្ធិពលដ៏ជ្រៀលជ្រៅទៅលើអស់ទាំងមនុស្ស ដែលបានរស់នៅ ហើយដែលនឹងរស់នៅលើផែនដីនៅអនាគតកាល ៕

ព្រះអង្គគឺជាព្រះយេហូវ៉ា នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ហើយជាព្រះមែស៊ី នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ។ នៅក្រោមការដឹកនាំរបស់ព្រះវរបិតារបស់ទ្រង់ នោះព្រះអង្គគឺជាព្រះដ៏បង្កបង្កើតនៃផែនដី ។ «គ្រប់របស់ទាំងអស់បានកើតមកដោយសារទ្រង់ ហើយក្នុងបណ្ដារបស់ដែលបានកើតមកទាំងប៉ុន្មាន នោះគ្មានអ្វីណាមួយកើតមក ក្រៅពីទ្រង់ឡើយ (យ៉ូហាន ១:៣) ។ ទោះជាព្រះអង្គគ្មានបាបក៏ដោយ ក៏ទ្រង់បានទទួលបុណ្យជ្រមុជទឹកដើម្បីបំពេញនូវអស់ទាំងសេចក្ដីសុចរិតដែរ ។ ទ្រង់«បានយាងចុះឡើង ធ្វើការល្អ» (កិច្ចការ ១០:៣៨) ប៉ុន្តែត្រូវគេស្អប់ទៅវិញ ។ ដំណឹងល្អរបស់ទ្រង់គឺជាសារអំពីសេចក្ដីសុខសាន្ត និងសុជនភាព ។ ព្រះអង្គបានអង្វរមនុស្សគ្រប់រូបឲ្យធ្វើតាមគំរូរបស់ទ្រង់ ។ ព្រះអង្គបានយាងតាមថ្នល់ស្រុកភីលីស្ទីន ដើម្បីព្យាបាលអ្នកឈឺ ធ្វើឲ្យអ្នកខ្វាក់មើលឃើញ ហើយប្រោសមនុស្សស្លាប់ឲ្យរស់ឡើងវិញ ។ ព្រះអង្គបានបង្រៀនពីសេចក្ដីពិតនៃភាពអស់កល្ប ពីភាពពិតប្រាកដនៃជីវិតរបស់យើង ដែលមានមុនផែនដី ពីគោលបំណងនៃជីវិតរបស់យើងនៅលើផែនដី និងពីលទ្ធភាពលូតលាស់ ចំពោះបុត្រាបុត្រីទាំងឡាយនៃព្រះនៅក្នុងជីវិតខាងមុខ ៕

ព្រះអង្គបានចាត់តាំងឲ្យមានបុណ្យសាក្រាម៉ង់ឡើង ដើម្បីទុកជាការរំឭកចាំអំពីការបូជាដ៏មហិមារបស់ទ្រង់ ដែលធួននឹងបាប ។ ព្រះអង្គត្រូវគេចាប់ ហើយកាត់ទោសពីរឿងមិនសមរម្យថ្កោលទោស ដើម្បីបំពេញចិត្តមនុស្ស ហើយកាត់ក្ដីឲ្យសុគតនៅលើឈើឆ្កាងត្រង់ភ្នំកាល់វ៉ារី ។ ព្រះអង្គបានប្រទានព្រះជន្មរបស់ទ្រង់ ដើម្បីធ្វើឲ្យធួននឹងអំពើបាបទាំងឡាយនៃមនុស្សទាំងអស់ ។ ព្រះជន្មរបស់ទ្រង់គឺជាអំណោយទានជំនួសមនុស្សទាំងអស់ ដែលធ្លាប់បានរស់នៅលើផែនដី ៕

យើងសូមថ្លែងទីបន្ទាល់ដោយមុឹងម៉ាត់ថា ព្រះជន្មរបស់ទ្រង់ ដែលជាសារៈសំខាន់បំផុតនៅក្នុងប្រវត្តិសាស្ត្រមនុស្ស នោះពុំមែនចាប់ផ្ដើមនៅភូមិបេថ្លេហិម ឬបញ្ចប់នៅភ្នំកាល់វ៉ារីនោះទេ ។ ព្រះអង្គគឺជាព្រះរាជបុត្រាច្បងបង្អស់នៃព្រះវរបិតា ជាព្រះរាជបុត្រាបង្កើតតែមួយនៅក្នុងសាច់ឈាម ជាព្រះដ៏ប្រោសលោះនៃពិភពលោក ៕

ព្រះអង្គបានមានព្រះជន្មរស់ឡើងពីផ្នូរ ដើម្បី«ជាផលដំបូងពីពួកអ្នកដែលបានដេកលក់ទៅហើយ» (១ កូរិនថូស ១៥:២០) ។ ជាព្រះអង្គដែលមានព្រះជន្មរស់ឡើងវិញ នោះទ្រង់បានយាងទៅជួបពួកអ្នកដែលទ្រង់បានស្រឡាញ់ ក្នុងកាលមានព្រះជន្មរស់នៅ ។ ព្រះអង្គក៏បានទៅបំរើនៅចំណោម «ចៀមឯទៀត» របស់ទ្រង់ (យ៉ូហាន ១០:១៦) នៅទ្វីបអាមេរិកពីជំនាន់បុរាណ ។ នៅក្នុងពិភពលោកជំនាន់ថ្មី ព្រះអង្គនិងព្រះវរបិតារបស់ទ្រង់បានលេចមកឲ្យក្មេងប្រុសម្នាក់ឈ្មោះ យ៉ូសែបស្ម៊ីធឃើញ ដើម្បីអញ្ជើញនូវ«ការកាន់កាប់គ្រួតត្រា នៃពេលពេញកំណត់» ដែលបានសន្យាទុកជាយូរយាមកហើយ (អេភេសូរ ១:១០) ៕

ស្ដីអំពីព្រះគ្រីស្ទដែលមានព្រះជន្មរស់នៅ នោះព្យាការីយ៉ូសែបស្ម៊ីធបានកត់ទុកថា៖ «ព្រះនេត្ររបស់ទ្រង់ហាក់ដូចជាអណ្ដាតភ្លើង ព្រះកេសារបស់ទ្រង់ហាក់ដូចជាហិមៈសសុទ្ធ ព្រះភ័ក្ត្ររបស់ទ្រង់បានចែងចាំងជាងរស្មីនៃព្រះអាទិត្យ ហើយព្រះសូរសៀងរបស់ទ្រង់ហាក់ដូចជាសម្លេងនៃទឹកហូរដ៏មហិមា គឺព្រះសូរសៀងនៃព្រះយេហូវ៉ាមានបន្ទូលថា៖

«យើងជាដើមហើយជាចុង យើងនេះហើយជាអ្នកដែលមានព្រះជន្មរស់ យើងនេះហើយជាអ្នកដែលត្រូវគេធ្វើគត យើងនេះហើយជាអ្នកដែលទូលអង្វរជំនួសអ្នក ជាមួយនឹងព្រះវរបិតា» (គ. និង ស. ១១០:៣-៤) ៕

ស្ដីអំពីព្រះអង្គ លោកព្យាការីក៏បានថ្លែងប្រាប់ដែរថា៖ «ហើយឥឡូវនេះ បន្ទាប់ពីទីបន្ទាល់ជាច្រើនដែលបានថ្លែងអំពីទ្រង់ នេះគឺជាទីបន្ទាល់ចុងក្រោយបង្អស់ ដែលយើងសូមថ្លែងអំពីទ្រង់៖ ថាទ្រង់មានព្រះជន្មរស់!

«ត្បិតយើងបានឃើញទ្រង់ គង់នៅខាងស្ដាំព្រះហស្តនៃព្រះ ហើយយើងបានឮសម្លេងដែលថ្លែងទីបន្ទាល់ថា ទ្រង់គឺជាបុត្រាបង្កើតតែមួយនៃព្រះវរបិតា—

«ថាដោយសារព្រះអង្គ ហើយតាមរយៈព្រះអង្គ ហើយពីព្រះអង្គ នោះភិភពលោកទាំងឡាយត្រូវបានបង្កើតឡើង ហើយពួកអ្នកដែលអាស្រ័យនៅទីនោះ គឺជាបុត្រាបុត្រីបង្កើតទាំងឡាយចំពោះព្រះ» (គ. និង ស. ៧៦:២២-២៤) ៕

យើងសូមថ្លែងដោយនូវពាក្យដ៏មុឹងម៉ាត់ថា បព្វជិតភាពរបស់ទ្រង់ និងពួកជំនុំរបស់ទ្រង់ត្រូវបានសាងឡើងវិញនៅលើផែនដី—«ដែលបានស្អាងឡើងលើជើងជញ្ជាំងនៃ. . . ពួកសាវកនិងពួកព្យាការី ហើយព្រះយេស៊ូវគ្រីស្ទនោះឯង ទ្រង់ជាថ្មជ្រុងយ៉ាងឯក» (អេភេសូរ ២:២០) ៕

យើងសូមធ្វើទីបន្ទាល់ថាថ្ងៃណាមួយ នោះទ្រង់នឹងយាងមកផែនដីវិញ ។ «នោះសិរីល្អនៃព្រះអម្ចាស់នឹងសម្ដែងមក គ្រប់មនុស្សទាំងឡាយនឹងបានឃើញព្រមគ្នា» (អេសាយ ៤០:៥) ។ ព្រះអង្គនឹងគ្រប់គ្រងជាស្ដេចលើអស់ទាំងស្ដេច ហើយសោយរាជ្យជាព្រះអម្ចាស់លើអស់ទាំងចៅហ្វាយ ហើយគ្រប់ទាំងជង្គង់នឹងបន្ទាបចុះ ហើយគ្រប់ទាំងអណ្ដាតនឹងចេញវាចាដោយនូវការថ្វាយបង្គំដល់ទ្រង់ ។ យើងនីមួយៗនឹងត្រូវឈរ ដើម្បីទទួលការជំនុំជំរះពីទ្រង់ ស្របតាមកិច្ចការរបស់យើងទាំងឡាយ និង តាមសេចក្ដីប៉ងប្រាថ្នានៃចិត្តរបស់យើងទាំងឡាយ ៕

យើងជាពួកសាវករបស់ទ្រង់ដែលបានតែងតាំងឡើងដោយត្រឹមត្រូវ សូមថ្លែងទីបន្ទាល់ — ថាព្រះយេស៊ូវគឺជាព្រះគ្រីស្ទដ៏មានព្រះជន្មរស់ និងជាព្រះរាជបុត្រាដ៏អមតៈរបស់ព្រះ ។ ព្រះអង្គគឺជាព្រះរាជាអេម៉ាញូអែលដ៏មហិមា ដែលសព្វថ្ងៃនេះ ឈរនៅខាងស្ដាំព្រះហស្តនៃព្រះវរបិតារបស់ទ្រង់ ។ ព្រះអង្គគឺជាពន្លឺ ជាជីវិត ហើយជាសេចក្ដីសង្ឃឹមនៃពិភពលោក ។ មាគ៌ារបស់ទ្រង់គឺជាផ្លូវដែលនាំទៅរកសុភមង្គលនៅក្នុងជីវិតនេះ និងនៅក្នុងជីវិតដ៏នៅអស់កល្បជានិច្ច នៅក្នុងលោកដែលនឹងមកដល់ ។ សូមអរព្រះគុណដល់ព្រះ ចំពោះអំណោយទានដ៏ប្រៀបផ្ទឹមពុំបាន នៃព្រះរាជបុត្រារបស់ទ្រង់ដ៏ឧត្ដម ៕ ៚

**គណៈប្រធានទីមួយ**



១ មករា ២០០០

**ក្រុមនៃពួក១២នាក់**



